គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC – BCV-CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CJR- CSD - CWCC - GENEROUS - HROTP
IDA_KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC - OUTREACH – PDP - PJJ - TASK FORCE - VIGILANCE
#09, St 330, Sangkat Boeung Keng Kang3, Khan Chamcar Mon, Phnom Penh, Cambodia, Tel/Fax: 023 301 415 E-mail: chrac@forum.org.kh

# សេចក្តីប្រកាសព័ត៌មាន

## គណៈកម្មាធិការប្រព្រឹត្តិកម្មអំពាវនាវឱ្យអង្គជំនុំជម្រះវិសាមញ្ញជ្រើសរើសជាបន្ទាន់នូវប្រធានថ្មីរបស់អង្គភាពគាំពារជនរងគ្រោះ

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ដែលមានសមាជិកចំនួន ២៣ ធ្វើការលើវិស័យសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ សូមសំដែងនូវការព្រួយបារម្ភចំពោះការយឺតយ៉ាវរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) ក្នុងការរៀបចំជ្រើសរើសប្រធានថ្មីរបស់អង្គភាពគាំពារជនរងគ្រោះ។ អង្គការសង្គមស៊ីវិលដទៃ រួមទាំងសមាជិករបស់គណៈកម្មាធិការប្រព្រឹត្តិកម្ម បានជួយគាំទ្រការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការរបស់សាលាក្តីនេះ ហើយ ក៏បានចូលរួមចំណែកជំរុញឱ្យជនរងគ្រោះចូលរួមដាក់ពាក្យបណ្តឹងទៅកាន់តុលាការ ដែលខណៈបច្ចុប្បន្ននេះ មានរហូតដល់ទៅជាង ៨000 នាក់ សំរាប់សំណុំរឿង 00២ ដែលជាសំណុំរឿងមួយដ៏មានសារៈសំខាន់បំផុត។ តំណាក់កាលនេះ គឺជាតំណាក់កាលដ៏មានសារៈសំខាន់សំរាប់ឱ្យអង្គជំនុំជម្រះវិសាមញ្ញ ប៉ុន្តែផ្ទុយទៅវិញ ប្រធានថ្មីដែលមានសមត្ថភាពសំរាប់ធ្វើការដឹកនាំអង្គភាពគាំពារជនរងគ្រោះ នៅមិនទាន់ជ្រើសរើសបាននៅឡើយ។

បន្ទាប់ពីការប្រកាសលាលែងរបស់ប្រធានអង្គភាពគាំពារជនរងគ្រោះ ដែលបានធ្វើឡើងនៅដើមខែឧសភា ឆ្នាំ២០១០ កន្លងទៅនេះ តុលាការបានសន្យាថា ការស្វែងរកអ្នកថ្មីជំនួសតំណែងនេះ “នឹងអាចធ្វើឡើងដោយអនុឡោមទៅតាមគោលការណ៍ជ្រើសរើសបុគ្គលិករបស់តុលាការ ដែលតំរូវឱ្យមានការជ្រើសរើសមួយប្រកបដោយលក្ខណៈប្រកួតប្រជែង” (យោងតាមអត្ថបទផ្សាយនៅក្នុងទំព័រកាសែតខេមបូឌា ដេលី ចុះថ្ងៃទី0៦ ខែឧសភា ឆ្នាំ២០១០)។ តែទោះបីជាយ៉ាងណាក៏ដោយ អស់រយៈពេលជាងពីរខែកន្លងមកហើយ គេនៅមិនទាន់ឃើញមាននូវចំណាត់ការណាមួយ ដែលខាងការិយាល័យរដ្ឋបាលរបស់តុលាការផ្តួចផ្តើមឱ្យមានដំណើរការជ្រើសរើសអ្នកថ្មីជំនួសនៅឡើយទេ។ ទោះបីជាបច្ចុប្បន្ននេះ យើងសង្កេតឃើញថា ការិយាល័យរដ្ឋបាលបានតែងតាំងជាបណ្តោះអាសន្ននូវប្រធានស្តីទីសំរាប់អង្គភាពនេះក៏ដោយ ក៏ប៉ុន្តែយើងជឿជាក់ថា មានតែមន្ត្រីជាន់ខ្ពស់ដែលមានសមត្ថភាពបំពេញតួនាទីពេញម៉ោង និងមានបទពិសោធន៏ធ្វើការជាមួយនឹងជនរងគ្រោះ ទើបអាចដោះស្រាយបានយ៉ាងពេញលេញជាមួយនឹងជនរងគ្រោះចំនួនរាប់ពាន់នាក់ ដែលបានចូលរួមនៅក្នុងដំណើរការនីតិវិធីសំណុំរឿង00២ បាន។

បញ្ហាប្រឈមជាច្រើននៅពេលខាងមុខទាក់ទិននឹងការចូលរួមរបស់ជនរងគ្រោះនេះ វាទាមទារជាបន្ទាន់ឱ្យមានប្រធានថ្មី ដែលមានសមត្ថភាព និងធ្វើការពេញម៉ោងសំរាប់អង្គភាពគាំពារជនរងគ្រោះ។ ពីព្រោះថា បញ្ហា

ប្រឈមទាំងនោះ មានជាអាទិ៍ដូចជា: ការជួយបញ្ជូនសេចក្តីសំរេចរាប់ពាន់ទៅលើការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២, ការជួយសំរបសំរួលការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីរាប់រយនាក់ ឬអាចមានរាប់ពាន់នាក់នៅក្នុងសំណុំរឿង០០២ ដែលក្នុងនោះក៏ត្រូវការឱ្យមានការបង្កើតឱ្យមានប្រព័ន្ធទំនាក់ទំនងប្រកបដោយប្រសិទ្ធិភាព និង គាំទ្រឱ្យមានការចូលរួមស្តាប់នៅក្នុងសវនាការ ព្រមទាំងផ្តល់ការគាំទ្រឱ្យបានពេញលេញទៅដល់ការងាររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ជាដើម។ លើសពីនេះទៀត គេនៅមិនទាន់ឃើញមានការរីកចំរើននៅឡើយក្នុងរយ:ពេល ៩ ខែ កន្លងមក ទាក់ទិននឹងអាណត្តិថ្មីរបស់អង្គភាពគាំពារជនរងគ្រោះ នៅក្នុងការបង្កើត និងអនុវត្តន៍នូវគំរោងនានាដែលមិនមានលក្ខណ:ផ្លូវច្បាប់ ដើម្បីជាប្រយោជន៍របស់ជនរងគ្រោះ ដោយធ្វើការសហការជាមួយនឹងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនានា ក្រៅពីអង្គជំនុំជម្រះវិសាមញ្ញ។

បញ្ហាប្រឈមទាំងនេះទាមទារចាំបាច់ឱ្យអង្គភាពនេះមានលក្ខណ:រឹងមាំនិងសកម្ម ដែលទទួលនូវការគាំទ្រយ៉ាងពេញលេញពីការិយាល័យរដ្ឋបាលនៅក្នុងការអនុវត្តន៍នូវអាណត្តិការងាររបស់ខ្លួន ដើម្បីជួយដល់អ្នកទទួលផលទាំងឡាយអំពីការកាត់សេចក្តីនេះ ដែលជាជនរងគ្រោះទាំងអស់នៃរបបខ្មែរក្រហម។ ទន្ទឹមនឹងនេះ វាជាការវិវត្តន៍ដ៏គួរឱ្យសរសើរផងដែរ ដែលថា នាពេលថ្មីៗនេះ រដ្ឋាភិបាលអាឡឺម៉ង់ទើបតែបានផ្តល់វិភាគទានថវិកាបន្ថែមទៀតទៅឱ្យអង្គភាពគាំពារជនរងគ្រោះនេះ។ ដូចនេះ ពេលវេលានេះ គឺជាពេលដែលត្រូវប្រើប្រាស់ថវិកាទាំងនោះឱ្យមានប្រសិទ្ធិភាពសំរាប់គោលបំណងនានា ដែលចែងទទួលស្គាល់នៅក្នុងកិច្ចព្រមព្រៀងទ្វេភាគីរវាងអង្គភាពនេះជាមួយនឹងម្ចាស់ជំនួយ។

ដូចនេះ គណ:កម្មាធិការប្រព្រឹត្តិកម្ម សូមធ្វើការអំពាវនាវដល់ការិយាល័យរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ មេត្តាចាត់វិធានការដូចខាងក្រោម:

១- ផ្តួចផ្តើមដំណើរការជ្រើសរើសប្រធានថ្មីរបស់អង្គភាពគាំពារជនរងគ្រោះ ដែលមានបទពិសោធន៍ធ្វើការលើកស្ទួយសិទ្ធិរបស់ជនរងគ្រោះ ប្រកបដោយតម្លាភាព និងជាបន្ទាន់ ដោយមិនពន្យាពេលតទៅទៀត។

២- បញ្ចប់ដំណើរការជ្រើសរើសសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីថ្មីដែលគាំទ្រថវិកាដោយតុលាការ ដើម្បីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលមិនទាន់មានមេធាវី។

៣- ផ្តល់ការគាំទ្រឱ្យបានពេញលេញដល់អង្គភាពគាំពារជនរងគ្រោះ ដើម្បីឱ្យអង្គភាពនេះបំពេញអាណត្តិរបស់ខ្លួនក្នុងការអនុវត្តន៍វិធានការដែលមិនមានលក្ខណ:ផ្លូវច្បាប់ និងសំណងសមូហភាព បានដោយជោគជ័យ។

*ភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០*


*សំរាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:*

| | | |
|---|---|---|
| លោក ហង្ស ឆាយា | ប្រធានសំរបសំរួល CHRAC និងនាយក KID | ទូរស័ព្ទលេខ: ០១២ ៩៧៥ ៨៨៣ |
| លោក ធន សារាយ | ប្រធានសមាគមអាដហុក | ទូរស័ព្ទលេខ: ០១២ ៩៧៥ ៨៨៣ |
| លោក សុក សំអឿន | នាយកប្រតិបត្តិរបស់ CDP | ទូរស័ព្ទលេខ: ០១២ ៩៧៥ ៨៨៣ |
| លោកស្រី សាយ វឌ្ឍនី | នាយិកាប្រតិបត្តិរបស់ CWC | ទូរស័ព្ទលេខ: ០១២ ៩៧៥ ៨៨៣ |
| លោកស្រី ស៊ុន ចាន់សែន | ប្រធានអង្គការ KYA | ទូរស័ព្ទលេខ: ០១២ ៩៧៥ ៨៨៣ |